# របាយការណ៍
# បូកសរុបស្តីពីសកម្មភាពការងារ
# របស់នាយកដ្ឋានបណ្តុះបណ្តាល និងស្រាវជ្រាវ
# ឆ្នាំ ២០២២ និងទិសដៅការងារឆ្នាំ ២០២៣

## ១. សេចក្តីផ្តើម

ការកសាងធនធានមនុស្សប្រកបដោយគុណភាព និងប្រសិទ្ធភាព រួមមានចំណេះដឹង ជំនាញច្បាស់លាស់ សីលធម៌ គុណធម៌ បញ្ញាស្មារតី ជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយចីរភាព និងភាពសុខដុម។ ដើម្បីសម្រេចបាននូវទស្សនវិស័យនេះ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ឈ្លាសវៃ និងបញ្ញាញាណដ៏ភ្លឺស្វាងរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** បានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ សម្រាប់រាជរដ្ឋាភិបាលនីតិកាលទី ៦ នៃរដ្ឋសភា ដែលបានកំណត់ ការអភិវឌ្ឍធនធានមនុស្សនៅក្នុងជ្រុងទី១ នៃយុទ្ធសាស្ត្រចតុកោណ។ ធនធានមនុស្សជាគន្លឹះសម្រាប់ទ្រទ្រង់សេដ្ឋកិច្ច កិច្ចអភិវឌ្ឍន៍ ភាពប្រកួតប្រជែងរបស់ប្រទេសជាតិទាំងក្នុងពេលបច្ចុប្បន្ន និងទាំងក្នុងពេលអនាគត។

តាំងពីមុនរហូតដល់យុគ្គសម័យបច្ចេកវិជ្ជាទំនើបនេះ ធនធានមនុស្សគឺជាមូលដ្ឋានគ្រឹះ ដែលមិនអាចខ្វះបាននៅក្នុងដំណើរការនៃការអភិវឌ្ឍប្រទេសជាតិ។ ប្រការនេះ តម្រូវឱ្យរាជរដ្ឋាភិបាលនីតិកាលទី ៦ បានយកចិត្តទុកដាក់កាន់តែខ្លាំងឡើងលើការវិនិយោគ "**មូលធនពុទ្ធិ**" ពោលគឺការអភិវឌ្ឍ "**មូលធនមនុស្ស**" សំដៅធានាបង្កើនគុណភាព ដែលជាកត្តាក្នុងការកំណត់ភាពប្រកួតប្រជែងរយៈពេលវែងរបស់ប្រទេសជាតិ ដើម្បីទាញយកផលប្រយោជន៍ និងប្រើប្រាស់ឱ្យអស់លទ្ធភាពនូវសក្តានុពលធនធានមនុស្សរបស់កម្ពុជាសម្រាប់ ធានាចីរភាពនៃកំណើនសេដ្ឋកិច្ច វឌ្ឍនភាព និងវិបុលភាពប្រជាពលរដ្ឋ។

ដើម្បីរួមចំណែកសម្រេចឱ្យបាន នូវទស្សនវិស័យនៃគោលនយោបាយ របស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងអភិវឌ្ឍន៍ជនបទ ក្រោមការដឹកនាំដ៏ត្រឹមត្រូវរបស់**ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន** ជារដ្ឋមន្ត្រី បាននិងកំពុងយកចិត្តទុកដាក់អនុវត្តការងារយ៉ាងសកម្ម ដោយទទួលបានជោគជ័យជាបន្តបន្ទាប់តាមកម្មវិធី យុទ្ធសាស្ត្រ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ដោយឡែកការងារអភិវឌ្ឍធនធានមនុស្ស ក្រសួងអភិវឌ្ឍន៍ជនបទបានដាក់ចេញ នូវគោលនយោបាយអភិវឌ្ឍន៍ធនធានមនុស្ស នៅក្នុងឆ្នាំ២០១២ ដើម្បីឆ្លើយតបទៅនឹងនិន្នាការនៃវិវឌ្ឍនាការក្នុងប្រទេស ក្នុងតំបន់ និងសកលលោក នៃការធ្វើឱ្យប្រសើរឡើងនូវ ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងនិរន្តរភាព។ ទន្ទឹមគ្នានោះ ឯកសារផែនការយុទ្ធសាស្ត្ររយៈពេល ៥ ឆ្នាំក្រសួងអភិវឌ្ឍន៍ជនបទក៏បានកំណត់សកម្មភាពជាយុទ្ធសាស្ត្រសំខាន់ៗ ចំនួន ៤ ដែលក្នុងនោះការអភិវឌ្ឍធនធានមនុស្ស គឺសកម្មភាពជាយុទ្ធសាស្ត្រ

ដែលមានអាទិភាពខ្ពស់បំផុត សម្រាប់គាំទ្រដល់សកម្មភាពជាយុទ្ធសាស្ត្រ ៣ ផ្សេងទៀតនៅក្នុងវិស័យអភិវឌ្ឍន៍ជនបទ។

គោលនយោបាយអភិវឌ្ឍន៍ធនធានមនុស្ស គឺជាមូលដ្ឋានគ្រឹះសម្រាប់កសាងធនធានមនុស្សរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវបានបែងចែកជាពីរសំខាន់ទី១ កសាងសមត្ថភាពមន្ត្រីរាជការតាមរយៈការរៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាល ទស្សនកិច្ចសិក្សា ដើម្បីផ្លាស់ប្តូរបទពិសោធន៍ ការសិក្សារយៈពេលវែង និងការបណ្តុះបណ្តាលនៅនឹងកន្លែងទី២ កសាងសមត្ថភាពប្រជាជននៅតាមមូលដ្ឋានជនបទតាមរយៈការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈមូលដ្ឋានដែលក្នុងនោះ ដែលក្រសួងបានបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋាន បានចំនួន ១១ ខេត្ត ស្មើនឹង ១១ កន្លែង គិតមកដល់ឆ្នាំ ២០២២។ ជារួម ក្រសួងបានចូលរួមចំណែកយ៉ាងសកម្ម ក្នុងការកសាងសង្គមជាតិ ជាពិសេសការកាត់បន្ថយភាពក្រីក្រ ដ៏មានប្រសិទ្ធភាពស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។

ដើម្បីសម្រេចបាននូវគោលនយោបាយខាងលើនេះ នាយកដ្ឋានបណ្តុះបណ្តាល និងស្រាវជ្រាវ បាននិងកំពុងសហការជាមួយដៃគូអភិវឌ្ឍន៍ និងនាយកដ្ឋានពាក់ព័ន្ធ ក៏ដូចជាមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី-ខេត្ត ដើម្បីជួយគាំទ្រដល់ការកសាងសមត្ថភាព និងអភិវឌ្ឍន៍ធនធានមនុស្សដល់មន្ត្រីទៅតាមតម្រូវការណ្តុះបណ្តាលរបស់មន្ត្រីរាជការ ព្រមទាំងប្រជាជននៅមូលដ្ឋានជនបទ ឱ្យមានចំណេះ និងជំនាញគ្រប់គ្រាន់ក្នុងការបំពេញភារកិច្ច និងប្រកបរបរចិញ្ចឹមជីវិត។

## ២. ស្ថានភាពមន្ត្រីរាជការ

នាយកដ្ឋានបណ្តុះបណ្តាល និងស្រាវជ្រាវ មានមន្ត្រីបម្រើការងារសរុបចំនួន ៤០ នាក់ ក្នុងនោះស្រីចំនួន ០៦ នាក់។

| ល.រ | អង្គភាព | ចំនួនមន្ត្រីរាជការ | | | មុខងារ | | | បម្រើការនៅក្រៅ | |
|---|---|---|---|---|---|---|---|---|---|
| | | ប | ស | សរុប | ប្រធាន | អនុប្រធាន | មន្ត្រី | ប | ស |
| ១ | ថ្នាក់ដឹកនាំនាយកដ្ឋាន | ៧ | ២ | ៩ | ១ | ៨ | ០ | ០ | ០ |
| ២ | ការិ.កិច្ចការទូទៅ | ៥ | ១ | ៦ | ១ | ៣ | ២ | ០ | ០ |
| ៣ | ការិ.បណ្តុះបណ្តាល | ៥ | ៣ | ៨ | ១ | ៤ | ៣ | ១ | ១ |
| ៤ | ការិ.ស្រាវជ្រាវ | ៦ | ០ | ៦ | ១ | ៣ | ២ | ១ | ០ |
| ៥ | ការិ.ផ្សព្វផ្សាយ | ៦ | ០ | ៦ | ១ | ៤ | ១ | ០ | ០ |
| ៦ | ការិ.មជ្ឈមណ្ឌលបណ្តុះបណ្តាល | ៥ | ០ | ៥ | ១ | ៣ | ១ | ០ | ០ |
| សរុប | | **៣៤** | **៦** | **៤០** | **៦** | **២៥** | **៩** | **២** | **១** |

ក. ចំនួនមន្ត្រីរាជការស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស ៖ ០០ នាក់

ខ.ចំនួនមន្ត្រីរាជការកំពុងសហការជាមួយអង្គការដៃគូ ៖ ០៣ នាក់

គ.ចំនួនមន្ត្រីរាជការគ្រប់ខណ្ឌថ្មី ៖ ០៣ នាក់

ឃ. ចំនួនមន្ត្រីរាជការផ្ទេរចេញ ៖ ០២ នាក់

## ៣. លទ្ធផលការងារឆ្នាំ ២០២២

### ៣.១ ការងារកិច្ចការទូទៅ

ក្នុងរយៈពេល ១២ខែ ក្នុងឆ្នាំ ២០២២ នេះ ការិយាល័យកិច្ចការទូទៅអនុវត្តបាន ៖

- ថ្នាក់ដឹកនាំនាយកដ្ឋានបានចូលរួមប្រជុំ និងសិក្ខាសាលាជាមួយថ្នាក់ដឹកនាំក្រសួង និងស្ថាប័នផ្សេងៗ ប្រជុំបូកសរុបសកម្មភាពការងារប្រចាំខែ-ទិសដៅបន្តរបស់នាយកដ្ឋាន សរុបចំនួន ៣០ លើក ប្រជុំដោយផ្ទាល់ ២៧លើក និងតាមរយៈ Online(Zoom Meeting) ០៣លើក
- ទទួលលិខិតចូលក្នុងអង្គភាពបានចំនួន ១២៩ លើក ( ពីលេខ ០០១ ដល់លេខ ១២៩ )
- ទទួលលិខិតចូលក្រៅអង្គភាពបានចំនួន ៦១ លើក ( ពីលេខ ០០១ ដល់លេខ ០៦១ )
- កសាងលិខិតចេញ(ប្រភេទលិខិតទូទៅ)បានចំនួន ១០០ លិខិត ( ពីលេខ ០០១ ដល់លេខ ១០០ )
- កសាងលិខិតចេញ (របាយការណ៍ បេសកកម្ម) បានចំនួន ៥៧លិខិត ( ពីលេខ ០០១ ដល់លេខ ០៥៧ )។

## ៣.២ ការងារបណ្តុះបណ្តាលមន្ត្រីរាជការ

ក្របខណ្ឌនៃការអភិវឌ្ឍមូលធនមនុស្សក្នុងក្រសួងអភិវឌ្ឍន៍ជនបទត្រូវបានអនុវត្តដោយអនុលោមតាមគោលនយោបាយ និងផែនការយុទ្ធសាស្ត្រដែលពាក់ព័ន្ធ។ ដោយហេតុផលក្នុងឆ្នាំទី១ នៃការបន្សាំបែបផែនការបណ្តុះបណ្តាលកាលលៈទេសៈបរិបទកូវីដ-១៩ សកលមិនទាន់បិទបញ្ចប់ទាំងស្រុង សម្រាប់ឆ្នាំ ២០២២ នេះ សកម្មភាពបណ្តុះបណ្តាលត្រូវបានដំណើរការក្នុងរូបភាពពីរយ៉ាងគឺ ១ ). ការបណ្តុះបណ្តាល ២ ).ការសម្របសម្រួល និងកិច្ចសហការលើកម្មវិធីបណ្តុះបណ្តាលនានា។

### ៣.២.១. ការបណ្តុះបណ្តាលមន្ត្រីរាជការ

ក្នុងឆ្នាំ ២០២២ នេះ បរិបទកូវីដ-១៩ បានទប់ស្កាត់ស្ទើទាំងស្រុងទូទាំងប្រទេស ហើយចរន្តនៃសេដ្ឋកិច្ច និងសង្គមនានាត្រូវបានដំណើរការជាប្រក្រតីឡើងវិញ តែយ៉ាងណាវិធានការសុវត្ថិភាព និងការប្រយ័ត្ននៅតែបន្ត ដើម្បីបញ្ចៀសការរីករាលឡើងមកវិញនៅក្នុងសង្គម។ នៅក្នុងបរិបទនៃការអភិវឌ្ឍធនធានមនុស្ស ក្រសួងអភិវឌ្ឍន៍ជនបទបានបន្សាំ រៀនរស់ រៀនធ្វើការក្នុងបរិបទនេះ សកម្មភាពបណ្តុះបណ្តាលមួយចំនួនធំធ្វើឡើងពីចម្ងាយតាម ប្រព័ន្ធអនឡាញ( Online )។

សម្រាប់ឆ្នាំ ២០២២ មន្ត្រីរាជការក្រសួងអភិវឌ្ឍន៍ជនបទបានអភិវឌ្ឍន៍សមត្ថភាពក្នុងបរិបទពីរយ៉ាងគឺ វគ្គការបណ្តុះបណ្តាល និងសិក្ខាសាលា ( ពុំមានសកម្មភាពទស្សនៈកិច្ចសិក្សាឡើយ )។

ក្នុងឆ្នាំ ២០២២ នាយកដ្ឋានបណ្តុះបណ្តាល និងស្រាវជ្រាវបានរៀបចំវគ្គបណ្តុះបណ្តាល ចំនួន ០៣វគ្គ មានសិក្ខាកាមសរុប ១៤៨ នាក់ ស្រី ២៩ នាក់។ ដោយឡែកសម្រាប់ការបណ្តុះបណ្តាល និងសិក្ខាសាលារួមសម្រាប់ក្រសួងអភិវឌ្ឍន៍ជនបទ ទាំងអង្គភាពក្រោមឱវាទរៀបចំ និងក្រៅអង្គភាពរៀបចំ ទទួលបានលទ្ធផល ដូចខាងក្រោម៖

- មន្ត្រីរាជការបានចូលរួមវគ្គបណ្តុះបណ្តាលសរុបចំនួន ៦៩៦ នាក់ ស្រី ១៧ នាក់ ដែលការបណ្តុះបណ្តាលនេះប្រព្រឹត្តិទៅក្នុងប្រទេស ពុំមានក្រៅប្រទេស។
- កសាងលិខិតចេញ (របាយការណ៍ បេសកកម្ម) បានចំនួន ៥៧លិខិត ( ពីលេខ ០០១ ដល់លេខ ០៥៧ )។




| | វគ្គបណ្តុះបណ្តាល | សិក្ខាសាលា |
|---|---|---|
| សរុប | ៦៩៦ | ១៣៩០ |
| ស្រី | ១៧ | ១៧៨ |

– មន្ត្រីរាជការបានចូលរួមក្នុងសិក្ខាសាលាសរុបចំនួន ១៣៩០ នាក់ ស្រី ១៧៨ នាក់។ សិក្ខាសាលាប្រព្រឹត្តិទៅក្នុងប្រទេសទាំងស្រុង ពុំមានក្រៅប្រទេស។ សរុបជារួម មន្ត្រីរាជការក្រសួងអភិវឌ្ឍន៍ជនបទ ដែលបានចូលរួមវគ្គបណ្តុះបណ្តាលនិងសិក្ខាសាលា ទាំងក្នុងប្រទេស និងក្រៅប្រទេសពុំមាន -សរុបទាំងអស់ចំនួន **២០៤៣** នាក់/ ស្រី **១៨៨** នាក់ ។

### – *តារាងលទ្ធផលនៃការកសាងសមត្ថភាពមន្ត្រីរាជការក្រសួងអភិវឌ្ឍន៍ជនបទឆ្នាំ ២០២២*

| ល.រ | បរិយាយ | ស្ថាប័នរៀបចំ | សិក្ខាកាមសរុប | សិក្ខាកាមស្រី |
|---|---|---|---|---|
| ១ | មន្ត្រីទទួលបានការបណ្តុះបណ្តាលក្នុងប្រទេស | ស្ថាប័នក្រៅ ក.អ.ជ | ១១៣៣ | ១២៥ |
| | | ស្ថាប័នក្នុង ក.អ.ជ | ៩១០ | ៦៣ |
| ២ | មន្ត្រីទទួលបានការបណ្តុះបណ្តាលក្រៅប្រទេស | ក្រៅប្រទេស | ០ | ០ |
| *សរុប* | | | *២០៤៣* | *១៨៨* |

### *តារាងប្រៀបធៀបការបណ្តុះបណ្តាលមន្ត្រីរាជការឆ្នាំ ២០២១ និងឆ្នាំ ២០២២*

| ល.រ | បរិយាយ | ស្ថាប័នរៀបចំ | ឆ្នាំ២០២១ | | ឆ្នាំ២០២២ | | ភាពប្រែប្រួល | |
|---|---|---|---|---|---|---|---|---|
| | | | *សរុប* | *ស្ត្រី* | *សរុប* | *ស្ត្រី* | *សរុប* | *ស្ត្រី* |
| ១ | មន្ត្រីទទួលបានការបណ្តុះបណ្តាលក្នុងប្រទេស | ស្ថាប័នក្រៅ ក.អ.ជ | ២៣១ | ៣៨ | ១១៣៣ | ១២៥ | ៩០២ | ៨៧ |
| | | ស្ថាប័នក្នុង ក.អ.ជ | ២៨៦ | ៥៦ | ៩១០ | ៦៣ | ៦២៤ | ៧ |
| ២ | មន្ត្រីទទួលបានការបណ្តុះបណ្តាល ក្រៅប្រទេស | ក្រៅប្រទេស | ១ | ១ | ០ | ០ | -១ | -១ |
| *សរុប* | | | *៥១៨* | *៩៥* | ២០៤៣ | ១៨៨ | ***១៥២៥*** | ***៩៣*** |

លទ្ធផលសរុបសម្រាប់ឆ្នាំ ២០២២ នេះ ចំនួនសិក្ខាកាមចូលរួមសរុប ២០៤៣ នាក់ (ស្រីចំនួន ១៨៨នាក់)។ បើប្រៀបធៀបនឹងឆ្នាំ ២០២១ កន្លងមកនេះ ដែលមានសិក្ខាកាមចូលរួមចំនួន ៥១៨នាក់ (ស្រីចំនួន ៩៥នាក់) សឲ្យឃើញថាក្នុងឆ្នាំ ២០២២ ចំនួនសិក្ខាកាមសរុបបានកើនឡើងចំនួន ១៥២៥នាក់ គិតជាភាគរយស្មើនឹង **២៩៤%** ដែលក្នុងនោះស្រីកើនឡើង ចំនួន ៩៣នាក់គិតជាភាគរយស្មើនឹង **៩៨%**។







### ៣.២.២. ការសម្របសម្រួល និងកិច្ចសហការលើកម្មវិធីបណ្តុះបណ្តាលនានា

ដើម្បីឆ្លើយតបនឹងតម្រូវការនៃការកសាងសមត្ថភាព មន្ត្រីរាជការក្រសួងក្នុងឆ្នាំ ២០២២ នេះ នាយកដ្ឋានបណ្តុះបណ្តាល និងស្រាវជ្រាវ បានសម្របសម្រួល និងសហការជាមួយស្ថាប័ន និងអង្គភាពជាដៃ

គូសម្រាប់ការងារបណ្តុះបណ្តាលបានចំនួន ៧៥ លើក ក្នុងនោះរួមមាន៖ ១). ផ្សព្វផ្សាយ និងជ្រើសរើសបេក្ខជន ក្រោមកម្មវិធីអាហារូបករណ៍សម្រាប់ការសិក្សារយៈពេលវែង និងមធ្យមក្នុងប្រទេសចំនួន២៦ លើក ២).សម្របសម្រួល និងរៀបចំឯកសាររដ្ឋបាលរវាងក្រសួង និងស្ថាប័នដៃគូដើម្បីគាំទ្រដល់សកម្មភាពបណ្តុះបណ្តាលថ្នាក់ឧត្តមសិក្សា និងក្រោមឧត្តមសិក្សាសរុប ២៤ លើក និង ៣). រៀបចំឯកសារចាត់បញ្ជូនមន្ត្រីរាជការចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា ការសិក្សារយៈពេលវែង មធ្យមសរុបចំនួន ២៥ លើក ។

## ៣.៣ .ការងារសិក្សាស្រាវជ្រាវ

ការងារសិក្សាស្រាវជ្រាវ មានតួនាទីយ៉ាងសំខាន់ក្នុងការសិក្សាពីការងារអភិវឌ្ឍន៍ជនបទ ដើម្បីចងក្រងឯកសារផ្សេងៗ ដែលជាមូលដ្ឋានសម្រាប់ធ្វើការសិក្សាបន្ត និងជួយដល់ការកសាងសមត្ថភាពមន្ត្រីរាជការរបស់ក្រសួង ឱ្យមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តការងារអភិវឌ្ឍន៍ជនបទ ប្រកបដោយប្រសិទ្ធភាព និងគុណភាពខ្ពស់។

សម្រាប់ឆ្នាំ ២០២២ នេះ ការងារស្រាវជ្រាវ បានបន្តការសិក្សាស្រាវជ្រាវលើឯកសារនានា និងចុះស្វែងយល់តាមមន្ទីរអភិវឌ្ឍន៍ជនបទ លើតម្រូវការវគ្គបណ្តុះបណ្តាលជំនាញបន្ថែមដែលជាជំនួយដល់ការសិក្សាស្រាវជ្រាវតម្រូវការការអភិវឌ្ឍ សមត្ថភាពការងាររបស់អង្គភាពក្រោមឱវាទក្រសួង ដូចខាងក្រោម ៖

- បានបញ្ចប់ សិក្សាស្រាវជ្រាវ ប្រមូលឯកសារ និង ស្រង់ទិន្នន័យតាមប្រព័ន្ធគេហទំព័រ លើការកំណត់ទីតាំង វិទ្យាស្ថាន និង សាលាបណ្តុះបណ្តាលជំនាញដែលពាក់ព័ន្ធវិស័យអភិវឌ្ឍន៍ជនបទ
- បានរៀបចំបូកសរុប និងចងក្រងជាឯកសារទិន្នន័យ សម្រាប់មុខជំនាញ ទីតាំងរបស់ វិទ្យាស្ថាន និង សាលាបណ្តុះបណ្តាលជំនាញដែលពាក់ព័ន្ធវិស័យអភិវឌ្ឍន៍ជនបទ។

## ៣.៤ .ការងារផ្សព្វផ្សាយ

ចុះថត និងយកព័ត៌មានសកម្មភាពថ្នាក់ដឹកនាំនៃក្រសួងអភិវឌ្ឍន៍ជនបទ និងសកម្មភាពរបស់អង្គភាពក្រោមឱវាទក្រសួង បានចំនួន **៥៣** លើក រួមមាន ៖១).ចុះថតនិងស្រង់ព័ត៌មានសកម្មភាព**ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** និងថ្នាក់ដឹកនាំ នៅទីស្តីការក្រសួង អភិវឌ្ឍន៍ជនបទ ចំនួន **២៨** លើក និង ២).សកម្មភាព **ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** និងថ្នាក់ដឹកនាំក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងខេត្តនានាទូទាំង ២៥ រាជធានី ខេត្ត ចំនួន **២៧** លើក

### ៣.៤.១ សកម្មភាពផ្សព្វផ្សាយ

ផ្សព្វផ្សាយសកម្មភាពរបស់ **ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** និងថ្នាក់ដឹកនាំក្រសួងអភិវឌ្ឍន៍ជនបទបានចំនួន ១៨៤ លើក រួមមាន ៖ ១).ផ្សព្វផ្សាយតាមស្ថានីយ៍ទូរទស្សន៍ជាតិកម្ពុជា ចំនួន ៥៦លើក ២).ផ្សព្វផ្សាយតាមស្ថានីយ៍ ទូរទស្សន៍អប្សរាចំនួន ៥៨លើក ៣).ផ្សព្វផ្សាយតាមស្ថានីយ៍ ទូរទស្សន៍បាយ័ន ចំនួន ៦៦ លើក ៤).ផ្សព្វផ្សាយតាមស្ថានីយ៍ ទូរទស្សន៍ CNC ចំនួន ០២ លើក និង ៥).ផ្សព្វផ្សាយតាមស្ថានីយ៍ ទូរទស្សន៍ NTV ចំនួន ០២ លើក។

### ៣.៤.២ ការងារព្រឹត្តិបត្រព័ត៌មាន និងផ្សព្វផ្សាយ

នាយកដ្ឋានបណ្តុះបណ្តាល និងស្រាវជ្រាវបាន ចងក្រងឯកសារសម្រាប់រៀបចំព្រឹត្តប័ត្រព័ត៌មាន និងបោះពុម្ពឯកសាររួមមាន៖ ១).ទិនានុលេខន៍ប្រចាំឆ្នាំ ២០២៣ របស់ក្រសួងអភិវឌ្ឍន៍

ជនបទ ធ្វើការបោះពុម្ពរូបជាស្ពាព ២).ផ្សព្វផ្សាយតាមគេហទំព័ររបស់ក្រសួងអភិវឌ្ឍន៍ជនបទ និងគេហទំព័រកាសែត កម្ពុជាថ្មី រស្មីកម្ពុជា នគរធំ និងកោះសន្តិភាព ៣).រៀបចំនឹងបោះពុម្ពព្រឹត្តិប័ត្រ ២០២២ ឆ្នាំទី ១៤ លេខ ២៧. និង ២៨ ។

## ៣.៥ ការងារបណ្តុះបណ្តាលជំនាញ មូលដ្ឋាន

ការបណ្តុះបណ្តាលជំនាញមូលដ្ឋានជូនប្រជាពលរដ្ឋនៅតាមជនបទជាគោលបំណងមួយយ៉ាងសំខាន់របស់ក្រសួងអភិវឌ្ឍន៍ជនបទ សំដៅលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋនៅជនបទតាមរយៈការប្រើជំនាញមូលដ្ឋានដែលបានទទួលបានការបណ្តុះបណ្តាល។ បច្ចុប្បន្ននេះនាយកដ្ឋានបណ្តុះបណ្តាល និងស្រាវជ្រាវ មានមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋានចំនួន ១១ខេត្ត រួមមាន ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តកំពង់ចាម ខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តកំពត ខេត្តកំពង់ធំ ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ឆ្នាំង និងខេត្តកណ្តាល។

នៅក្នុងឆ្នាំ ២០២២ នាយកដ្ឋានបណ្តុះបណ្តាលបានបញ្ជូនមន្ត្រីចំនួន ០២ រូប ទៅសិក្សាជំនាញថែទាំនិងជួសជុលបរិក្ខាម៉ាស៊ីនត្រជាក់ដើម្បី ធ្វើជាគ្រូបង្គោលចុះត្រួតពិនិត្យសកម្មភាពការងារណ្តុះបណ្តាល តាមខេត្តបានចំនួន ៣ ខេត្តរួមមានខេត្ត ខេត្តកំពត ខេត្តសៀមរាបនិងខេត្តបន្ទាយមានជ័យ។ ជាមួយគ្នា នេះមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋានទាំង ១១ ខេត្ត បានធ្វើសកម្មភាព បណ្តុះបណ្តាលនិងមានទទួលបានលទ្ធផលដូចខាងក្រោម៖

### ៣.៥.១.ខេត្តស្វាយរៀង

មជ្ឈមណ្ឌលបានដំណើរការវគ្គបណ្តុះបណ្តាលរយៈពេលវែង និងរយៈពេលខ្លី មានចំនួន ១៧ វគ្គ សិក្ខាកាមសរុប ២៤៨ នាក់ ស្រី ១៤៤ នាក់ ដោយវគ្គបណ្តុះបណ្តាលរយៈពេលខ្លី មានចំនួន ៣ មុខវិជ្ជា ស្មើនឹង ១៥ វគ្គ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន **២២៥** នាក់ (ស្រី **១២៤** នាក់) រួមមាន៖ (១). បច្ចេកទេសកែច្នៃផលិតផលកសិកម្ម ៥វគ្គ សិក្ខាកាម ៧៥ នាក់ ស្រី ៦៦ នាក់ (២). បច្ចេកទេសធ្វើជីកំប៉ុស្តិ៍ និងការវេចខ្ចប់ចំនួន ៥ វគ្គ សិក្ខាកាម ៧៥ នាក់ ស្រី ៥៨ នាក់ (៣). ការថែទាំម៉ាស៊ីនកសិកម្មខ្នាតតូច ៥ វគ្គ សិក្ខាកាម ៧៥ នាក់ ស្រី ០ នាក់ ។ វគ្គបណ្តុះបណ្តាលរយៈពេលវែង មានចំនួន ២ មុខវិជ្ជា ស្មើនឹង ២ វគ្គ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន **២៣** នាក់ (ស្រី **៣០** នាក់) រួមមាន៖ (១). កាត់ដេរសម្លៀកបំពាក់បុរស-នារី ១ វគ្គ សិក្ខាកាម ១០ នាក់ ស្រី ១០ នាក់ (២). កុំព្យូទ័ររដ្ឋបាល ចំនួន ១ វគ្គ សិក្ខាកាម ១៣ នាក់ ស្រី ១០ នាក់ ។

### ៣.៥.២. ខេត្តព្រៃវែង

មជ្ឈមណ្ឌលបានដំណើរការវគ្គបណ្តុះបណ្តាលរយៈពេលវែង និងរយៈពេលខ្លី មានចំនួន ១៧ វគ្គ សិក្ខាកាមសរុប ២៥២ នាក់ ស្រី ១៣០ នាក់ ដោយវគ្គបណ្តុះបណ្តាលរយៈពេលខ្លី មានចំនួន ៥ មុខវិជ្ជា ស្មើនឹង ១៤ វគ្គ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន **២១០** នាក់ (ស្រី **៩៩** នាក់) រួមមាន ៖ (១). ជួសជុល ថែទាំម៉ាស៊ីនកសិកម្ម ២ វគ្គ សិក្ខាកាម ៣០ នាក់ ស្រី ៣ នាក់ (២). បច្ចេកទេសចិញ្ចឹមត្រី ៤ វគ្គ សិក្ខាកាម ៦០ នាក់ ស្រី ៣៧ នាក់ (៣). បច្ចេកទេសចិញ្ចឹមមាន់ ៤ វគ្គ សិក្ខាកាម ៦០ នាក់ ស្រី ៣៤នាក់ (៤).បច្ចេកទេសធ្វើជីកំប៉ុស្តិ៍ ៣វគ្គ សិក្ខាកាម ៤៥ នាក់ ស្រី ១៨ នាក់ (៥). បច្ចេកទេសបណ្តុះផ្សិតចំបើង ១ វគ្គ សិក្ខាកាម ១៥ នាក់ ស្រី ៧ នាក់។ វគ្គបណ្តុះបណ្តាល

រយៈពេលវែងមានចំនួន ៣ មុខវិជ្ជា ស្មើនឹង ៣ វគ្គ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន **៤២** នាក់ (ស្រី **៣១** នាក់) រួមមានៈ (១). អ៊ុតសក់កែសម្ផស្សនារី ១ វគ្គ សិក្ខាកាម ១៥ នាក់ ស្រី ១៥ នាក់ (២). កាត់ដេរសម្លៀកបំពាក់ ចំនួន ១ វគ្គ សិក្ខាកាម ១០ នាក់ ស្រី ១០ នាក់ (៣). កុំព្យូទ័ររដ្ឋបាល ចំនួន ១ វគ្គ សិក្ខាកាម ១៧ នាក់ ស្រី ៦ នាក់ ។

**៣.៥.៣. ខេត្តកំពង់ចាម**

មជ្ឈមណ្ឌលបានដំណើរការវគ្គបណ្តុះបណ្តាលរយៈពេលវែង និងរយៈពេលខ្លី មានចំនួន ៧ វគ្គ សិក្ខាកាមសរុប ១៧៨ នាក់ (ស្រី ៩១ នាក់) ដោយវគ្គបណ្តុះបណ្តាលរយៈពេលខ្លី មានចំនួន ៣ មុខវិជ្ជា ស្មើនឹង ៣ វគ្គ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន **៧៨** នាក់ (ស្រី **១៩**នាក់) រួមមានៈ (១).ចិញ្ចឹមមាន់ ១ វគ្គ សិក្ខាកាម ២៦ នាក់ ស្រី ៣ នាក់ (២).បណ្តុះបណ្តាលជីកំប៉ុស្ដិ៍ ១ វគ្គ សិក្ខាកាម ២៧ នាក់ ស្រី ៩ នាក់ (៣). ជួសជុល និងថែទាំអណ្តូងស្នប់ ១ វគ្គ សិក្ខាកាម ២៥ នាក់ ស្រី ៣ នាក់។ វគ្គបណ្តុះបណ្តាល រយៈពេលវែងមានចំនួន ៣ មុខវិជ្ជា ស្មើនឹង ៤ វគ្គ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន **១០០**នាក់ (ស្រី **៧៦** នាក់) រួមមានៈ (១). កុំព្យូទ័ររដ្ឋបាល ២ វគ្គ សិក្ខាកាម ៦០ នាក់ ស្រី ៤៣ នាក់ (២). ភាសាអង់គ្លេស ១ វគ្គ សិក្ខាកាម ២៥ នាក់ ស្រី ១៨ នាក់ (៣).កែសម្ផស្ស ១ វគ្គ សិក្ខាកាម ១៥ នាក់ ស្រី ១៥ នាក់ ។

**៣.៥.៤. ខេត្តបាត់ដំបង**

មជ្ឈមណ្ឌលបានដំណើរការវគ្គបណ្តុះបណ្តាលរយៈពេលវែង និងរយៈពេលខ្លី មានចំនួន ១១ វគ្គ សិក្ខាកាមសរុប ២៤០ នាក់ (ស្រី ៥៩ នាក់) ដោយវគ្គបណ្តុះបណ្តាលរយៈពេលខ្លី មានចំនួន ៤ មុខវិជ្ជា ស្មើនឹង ៩ វគ្គ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន **១៨០**នាក់ (ស្រី **៣៦** នាក់) រួមមានៈ (១).ថែទាំម៉ាស៊ីនកសិកម្មខ្នាតតូច ៦ វគ្គ សិក្ខាកាម ១២០ នាក់ ស្រី ០ នាក់ (២).ចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ ១ វគ្គ សិក្ខាកាម ២០ នាក់ ស្រី ១៣ នាក់ (៣). ស្ទូនដំណាំជាលក្ខណៈគ្រួសារ ១ វគ្គ សិក្ខាកាម ២០ នាក់ ស្រី ៩នាក់ (៤) .បណ្តុះផ្សិតចំបើង ១វគ្គ សិក្ខាកាម ២០ នាក់ ស្រី១៤នាក់។

វគ្គបណ្តុះបណ្តាល រយៈពេលវែងមានចំនួន ២ មុខវិជ្ជា ស្មើនឹង ២ វគ្គ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន **៦០** នាក់ (ស្រី **២៣** នាក់) រួមមានៈ (១). កុំព្យូទ័ររដ្ឋបាល ១ វគ្គ សិក្ខាកាម ៤០ នាក់ ស្រី ២៣ នាក់ (២).ជួសជុលគ្រឿងយន្តកសិកម្មខ្នាតតូច ១ វគ្គ សិក្ខាកាម ២០នាក់ ស្រី ០នាក់

**៣.៥.៥. ខេត្តពោធិ៍សាត់**

មជ្ឈមណ្ឌលបានដំណើរការវគ្គបណ្តុះបណ្តាលរយៈពេលវែង និងរយៈពេលខ្លី មានចំនួន ១១ វគ្គ សិក្ខាកាមសរុប ២៦៥ នាក់ (ស្រី ១១៣ នាក់) ដោយវគ្គបណ្តុះបណ្តាលរយៈពេលខ្លី មានចំនួន ៣ មុខវិជ្ជា ស្មើនឹង ៩ វគ្គ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន **២២៥** នាក់ (ស្រី **៩៥** នាក់) រួមមានៈ (១).ចិញ្ចឹមមាន់ ៣ វគ្គ សិក្ខាកាម ៧៥ នាក់ ស្រី ៤០ នាក់ (២).ស្ទូនដំណាំជាលក្ខណៈគ្រួសារ ២ វគ្គ សិក្ខាកាម ៥០ នាក់ ស្រី ៣៩ នាក់ (៣). ថែទាំម៉ាស៊ីនកសិកម្មខ្នាតតូច ៤ វគ្គ សិក្ខាកាម ១០០ នាក់ ស្រី ១៦ នាក់។ វគ្គបណ្តុះបណ្តាល រយៈពេលវែងមានចំនួន ១ មុខវិជ្ជា ស្មើនឹង ២ វគ្គ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន **៤០** នាក់ (ស្រី **១៨** នាក់) រួមមានៈ(១).កុំព្យូទ័ររដ្ឋបាល ២ វគ្គ សិក្ខាកាម ៤០ នាក់ ស្រី ១៨ នាក់។

**៣.៥.៦. ខេត្តកំពត**

មជ្ឈមណ្ឌលបានដំណើរការវគ្គបណ្តុះបណ្តាលរយៈពេលវែង និងរយៈពេលខ្លី មានចំនួន ៩ វគ្គ សិក្ខាកាមសរុប ១៨០ នាក់ (ស្រី ៩៩ នាក់) ដោយវគ្គបណ្តុះបណ្តាលរយៈពេលខ្លី មានចំនួន ៣ មុខវិជ្ជា ស្មើនឹង ៨ វគ្គ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន **៧៨** នាក់ (ស្រី **១៩**នាក់) រួមមាន៖ (១).ចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ ៣ វគ្គ សិក្ខាកាម ៦០ នាក់ ស្រី ៤៨ នាក់ (២).ជួសជុល និងថែទាំម៉ាស៊ីនគោយន្ត ២ វគ្គ សិក្ខាកាម ៤០ នាក់ ស្រី ០ នាក់ (៣). បច្ចេកទេសចិញ្ចឹមត្រីអណ្តែង ៣ វគ្គ សិក្ខាកាម ៦០ នាក់ ស្រី ៣៨ នាក់។ វគ្គបណ្តុះបណ្តាល រយៈពេលវែងមានចំនួន ១ មុខវិជ្ជា ស្មើនឹង ១ វគ្គ ដែលមានសិក្ខាកាមចូលរៀនសរុបចំនួន **២០**នាក់ (ស្រី **១៣** នាក់) រួមមាន៖ (១). កុំព្យូទ័ររដ្ឋបាល ១ វគ្គ សិក្ខាកាម ២០ នាក់ ស្រី ១៣ នាក់។

**៣.៥.៧. ខេត្តកំពង់ធំ**

មជ្ឈមណ្ឌលបានដំណើរការវគ្គបណ្តុះបណ្តាលរយៈពេលខ្លី មានចំនួន ៣ មុខវិជ្ជា ស្មើនឹង ៤ វគ្គ សិក្ខាកាមសរុប ៨០ នាក់ (ស្រី ៤៧ នាក់) រួមមាន៖ (១).ចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ ១ វគ្គ សិក្ខាកាម ៣៥ នាក់ ស្រី ៣៣ នាក់ (២).ការផលិតសាប៊ូលាងចាន ១ វគ្គ សិក្ខាកាម ១៥ នាក់ ស្រី ១៤ នាក់ (៣). ជួសជុល និងថែទាំគ្រឿងយន្តកសិកម្ម ២ វគ្គ សិក្ខាកាម ៣០ នាក់ ស្រី ០ នាក់។

**៣.៥.៨. ខេត្តបន្ទាយមានជ័យ** (មិនមានសកម្មភាព)

**៣.៥.៩. ខេត្តសៀមរាប**

មជ្ឈមណ្ឌលបានដំណើរការវគ្គបណ្តុះបណ្តាលរយៈពេលខ្លី មានចំនួន ២ មុខវិជ្ជា ស្មើនឹង ៣ វគ្គ សិក្ខាកាមសរុប ៦៥ នាក់ (ស្រី ២៣ នាក់) រួមមាន៖ (១).ជំនាញដំណាំគ្រួសារនិងជីកំប៉ុស្ត៍ ១ វគ្គ សិក្ខាកាម ២៥ នាក់ ស្រី ២១ នាក់ (២).ជួសជុល និងថែទាំគ្រឿងយន្តកសិកម្ម ២ វគ្គ សិក្ខាកាម ៤០ នាក់ ស្រី ២ នាក់ ។

**៣.៥.១០. ខេត្តកណ្តាល**

មជ្ឈមណ្ឌលបានដំណើរការវគ្គបណ្តុះបណ្តាលរយៈពេលខ្លី មានចំនួន ២ មុខវិជ្ជា ស្មើនឹង ២ វគ្គ សិក្ខាកាមសរុប ៤០ នាក់ (ស្រី ៦ នាក់) រួមមាន៖ (១).ចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ ១ វគ្គ សិក្ខាកាម ២០ នាក់ ស្រី ២ នាក់ (២).បច្ចេកទេសសួនបន្លែ ១ វគ្គ សិក្ខាកាម ២០ នាក់ ស្រី ៤ នាក់ ។

**៣.៥.១១. ខេត្តកំពង់ឆ្នាំង**

មជ្ឈមណ្ឌលបានដំណើរការវគ្គបណ្តុះបណ្តាលរយៈពេលខ្លី មានចំនួន ២ មុខវិជ្ជា ស្មើនឹង ១២ វគ្គ សិក្ខាកាមសរុប ២១២ នាក់ (ស្រី ៥២ នាក់) រួមមាន៖ (១).ជួសជុល និងថែទាំគ្រឿងយន្តកសិកម្មខ្នាតតូច ៨ វគ្គ សិក្ខាកាម ១៣២ នាក់ ស្រី ០១ នាក់ (២).ធ្វើសាប៊ូលាងចាន ៤ វគ្គ សិក្ខាកាម ៨០ នាក់ ស្រី ៥២ នាក់ ។

លទ្ធផលសរុបសម្រាប់ការបណ្តុះបណ្តាលជំនាញនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋាន ក្នុងឆ្នាំ២០២២ ជូនប្រជាជននៅជនបទសរុបបានចំនួន **១៧៦០ នាក់** (ស្រី **៧៦៤នាក់**) ស្មើនឹង ៨៨.៦៦ភាគរយ។ បើធៀបនឹងឆ្នាំ២០២១ ដែលមានសិក្ខាកាមសរុប **២១៩ នាក់** (ស្រី **១១៦ នាក់**) ស្មើនឹង ១០.០៩ ភាគរយឃើញថា សិក្ខាកាមមានការកើនឡើងសរុបចំនួន **១៥៤១ នាក់** ស្មើនឹង **៧៨.៥៧%** ។

## ៤. បញ្ហាប្រឈម និងសំណូមពរ

ក្នុងការអនុវត្តផែនការសកម្មភាពកន្លងមក នាយកដ្ឋានបណ្តុះបណ្តាល និងស្រាវជ្រាវបានជួបប្រទះបញ្ហា ការប្រឈម និងសំណូមពរ មួយចំនួនដូចតទៅ៖

- ខ្វះអគារសិក្សាសមរម្យ កន្លែងសម្រាប់សិក្ខាកាម និងបុគ្គលិកស្នាក់នៅ និងរោងជាសម្រាប់ហាត់ការ
- ខ្វះគ្រូបង្គោល ដែលមានជំនាញច្បាស់លាស់ នៅក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាល ជំនាញមូលដ្ឋាន
- ខ្វះឧបករណ៍ ឬសម្ភារឧបទ្ទេសសម្រាប់ជំនាញបណ្តុះបណ្តាលនីមួយៗ ឱ្យសមស្របតាមបច្ចុប្បន្នភាពបច្ចេកទេស
- ថវិកាសម្រាប់បម្រើការងារបណ្តុះបណ្តាលមានកម្រិត មិនទាន់ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង
- លំហូរថវិកាដែលមាន មានភាពយឺតយ៉ាវ និតិវិធីស្មុគស្មាញ និងមិនមានការកំណត់ពេលច្បាស់លាស់ ដែលធ្វើឲ្យមានការលំបាកក្នុងការអនុវត្តសកម្មភាពតាមផែនការ។
- បន្តកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីបញ្ជូនមន្ត្រីឱ្យចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា ទស្សនកិច្ចសិក្សា និងការសិក្សារយៈពេលវែង ដើម្បីលើកកម្ពស់សមត្ថភាពមន្ត្រី។

## ៥. ទិសដៅការងារសម្រាប់ឆ្នាំ ២០២៣

ដើម្បីឈានទៅសម្រេចបាននូវលទ្ធផលកាន់តែប្រសើរឡើងបន្ថែមទៀត នាយកដ្ឋានបណ្តុះបណ្តាល និងស្រាវជ្រាវ នឹងខិតខំបន្តសហប្រតិបត្តិការល្អជាមួយស្ថាប័នពាក់ព័ន្ធ និងអង្គការនានា ដើម្បីជំរុញការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្សដល់មន្ត្រីរាជការ និងប្រជាពលរដ្ឋក្រីក្រនៅជនបទឱ្យកាន់តែមានប្រសិទ្ធភាព និងបានកំណត់ទិសដៅសម្រាប់អនុវត្តក្នុងឆ្នាំ ២០២៣ មានដូចតទៅ ៖

### ៥.១. ការងារបណ្តុះបណ្តាលមន្ត្រី

ការិយាល័យបណ្តុះបណ្តាល បានកំណត់ផែនការបន្តសម្រាប់ឆ្នាំ ២០២៣ ក្នុងការពង្រឹងសមត្ថភាពលើការបណ្តុះបណ្តាលបមន្ត្រីក្រោមឱវាទក្រសួង និង ការបណ្តុះបណ្តាលជូនប្រជាពលរដ្ឋជនបទលើជំនាញមូលដ្ឋានចាំបាច់តាមតម្រូវការទីផ្សារបច្ចុប្បន្ន មានដូចតទៅ ៖

- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រអភិវឌ្ឍន៍សមត្ថភាពមន្ត្រីសម្របសម្រួលសហគមន៍ជនបទ ចំនួន ០២ វគ្គ សិក្ខាកាម ១១៤ នាក់
- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រស្រាវជ្រាវក្នុងការអភិវឌ្ឍជនបទ ចំនួន ០១ វគ្គ សិក្ខាកាម ៥៨ នាក់
- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីជំនាញសរសេររបាយការណ៍ និង កំណត់ហេតុ ចំនួន ០១ វគ្គ សិក្ខាកាម ៦០ នាក់
- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការបន្សាំនឹងការប្រែប្រួលអាកាសធាតុក្នុងការងារអភិវឌ្ឍជនបទ ចំនួន ០១ សិក្ខាកាម ៦០នាក់
- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការរៀបចំគម្រោងមេរៀនសម្រាប់មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋាន ចំនួន ០១ វគ្គ ៣៥ នាក់
- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រង និង ភាពជាអ្នកដឹកនាំ ចំនួន ០២ វគ្គ១១នាក់

- រៀបចំសិក្ខាសាលាស្តីពីការពង្រឹងសមត្ថភាពលើការគ្រប់គ្រងអង្គភាព ចំនួន ០២ វគ្គ សិក្ខាកាម ១៣៤ នាក់
- រៀបចំសិក្ខាសាលាចែករំលែកចំណេះដឹងដែលទទួលបានពីក្រៅប្រទេស ចំនួន ០២ វគ្គ សិក្ខាកាម ១៣៤ នាក់

## ៥.២.ការងារស្រាវជ្រាវ

ការិយាល័យស្រាវជ្រាវ បានកំណត់ផែនការបន្តសម្រាប់ឆ្នាំ ២០២៣ ក្នុងការពង្រឹងសមត្ថភាពលើការបណ្តុះបណ្តាលមន្ត្រីក្រោមឱវាទក្រសួង និង ការបណ្តុះបណ្តាលជូនប្រជាពលរដ្ឋជនបទលើជំនាញមូលដ្ឋានចាំបាច់តាមតម្រូវការទីផ្សារបច្ចុប្បន្ន មានដូចតទៅ ៖

- ស្រាវជ្រាវអំពីគុណផលនៃការងារបណ្តុះបណ្តាលទាំងមន្ត្រី និងប្រជាពលរដ្ឋ និងចងក្រងជាឯកសារទុកសម្រាប់បង្កើនប្រសិទ្ធភាពការងារបណ្តុះបណ្តាល
- ចុះថតសកម្មភាពពលរដ្ឋដែលបានបង្កើតមុខរបរដោយប្រើជំនាញមូលដ្ឋានតាមរយៈមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋាន និងចងក្រងជាឯកសារទុក
- រៀបចំផលិតព្រឹត្តិបត្រព័ត៌មានសម្រាប់ក្រសួងអភិវឌ្ឍន៍ជនបទ

## ៥.៣.ការងារផ្សព្វផ្សាយ

ដើម្បីឈានទៅសម្រេចបាននូវលទ្ធផលកាន់តែប្រសើរឡើងបន្ថែមទៀត និងជាការបំពេញបន្ថែមនូវចំណុចខ្វះខាតនានាអំពីការអនុវត្តការងារនាឆ្នាំ ២០២២ កន្លងមកការិយាល័យផ្សព្វផ្សាយបានកំណត់ទិសដៅសម្រាប់អនុវត្តក្នុងឆ្នាំ ២០២៣ មានដូចតទៅ ៖

- បន្តចុះស្រង់ព័ត៌មានស្តីពីសកម្មភាពថ្នាក់ដឹកនាំ និងកម្មវិធីតាមនាយកដ្ឋានជំនាញដើម្បីផ្សព្វផ្សាយតាមទូរទស្សន៍ ផលិតព្រឹត្តិបត្រព័ត៌មាន និងផ្សព្វផ្សាយតាមគេហទំព័រក្រសួង
- សិក្សាស្រាវជ្រាវ និងផ្សព្វផ្សាយព័ត៌មានជូនថ្នាក់ រាជធានី-ខេត្តទាំង២៥ ស្តីពី "ការផ្តល់ព័ត៌មានពីសកម្មភាពការងារតាមថ្នាក់ខេត្តនីមួយៗមកក្រសួង"នូវសកម្មភាពថ្នាក់ដឹកនាំ និងសមិទ្ធផលដែលក្រសួងសម្រេចបាននៅក្នុងសហគមន៍ដើម្បីធ្វើការផ្សព្វផ្សាយ តាមគេហទំព័រ និងតាមព្រឹត្តិបត្រ ក្រសួងអភិវឌ្ឍន៍ជនបទសម្រាប់ឆ្នាំ ២០២១
- បង្កើនការចងក្រង និងកែលម្អការរចនាការរៀបចំព្រឹត្តិបត្រព័ត៌មានឱ្យមានគុណភាព
- ចុះស្រង់ទិន្នន័យនិងព័ត៌មានស្តីពីវឌ្ឍនភាពវិស័យអភិវឌ្ឍន៍ជនបទនៅតាមសហគមន៍ជនបទ
- រៀបចំផលិតវីដេអូរឯកសារ និងវីដេអូរអប់រំខ្លីស្តីពីវិស័យអភិវឌ្ឍន៍ជនបទ។

## ៥.៤.ការងារបណ្តុះបណ្តាលជំនាញមូលដ្ឋាន

មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋានទាំង **១១** ខេត្ត បានលើកទិសដៅផែនការសម្រាប់ឆ្នាំ ២០២៣ ទាំងវគ្គរយៈពេលវែង និងវគ្គរយៈពេលខ្លីសរុបចំនួន **១០៨** វគ្គ មានដូចខាងក្រោម៖

**៥.៤.១. ខេត្តស្វាយរៀង** មានចំនួន **១៧ វគ្គ** ៖ (១). កុំព្យូទ័រដ្ឋបាល ១ វគ្គ (២). បរិក្ខាម៉ាស៊ីនត្រជាក់ ១ វគ្គ (៣). ដីកំប៉ុស្តិ៍និងការវិចខ្ចប់ ៥ វគ្គ (៣). ថែទាំគ្រឿងយន្តកសិកម្មខ្នាតតូច ១០ វគ្គ

**៥.៤.២. ខេត្តព្រៃវែង** មានចំនួន **២២ វគ្គ**៖ (១). អ៊ុតសក់ និងកែសម្ផស្ស ១ វគ្គ (២). កាត់ដេរសម្លៀកបំពាក់បុរស-នារី(៣).កុំព្យូទ័ររដ្ឋបាល ១ វគ្គ (៤).ចិញ្ចឹមមនិង

ព្យាបាលមាន់ ៤ វគ្គ (៥). ជីកំប៉ុស្ដិ៍ ៤ វគ្គ (៦). ចិញ្ចឹមត្រី ៤ វគ្គ (៧). បច្ចេកទេសបណ្តុះផ្សិតចំបើង ៤វគ្គ (៨).ជួសជុលម៉ាស៊ីនកសិកម្ម ៤ វគ្គ ។

**៥.៤.៣. ខេត្តកំពង់ចាម** មានចំនួន **៦ វគ្គ៖** (១). កាត់ដេរសម្លៀកបំពាក់ ១ វគ្គ (២). អ៊ុតសក់និងកែសម្ផស្ស ១ វគ្គ (៣). កុំព្យូទ័ររដ្ឋបាល ១ វគ្គ (៤). ចិញ្ចឹមនិងព្យាបាលមាន់ ១ វគ្គ (៥). ជីកំប៉ុស្ដិ៍ ១ វគ្គ ជួសជុលអណ្តូងស្នប់ ១ វគ្គ ។

**៥.៤.៦. ខេត្តបាត់ដំបង** មានចំនួន **១១ វគ្គ៖** (១).ជួសជុលគ្រឿងម៉ាស៊ីនខ្នាតតូច ១ វគ្គ (២).កុំព្យូទ័ររដ្ឋបាល ១ វគ្គ (៣).ចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ ១វគ្គ (៤). បណ្តុះផ្សិតចំបើង ១វគ្គ (៥).ថែទាំម៉ាស៊ីនកសិកម្មខ្នាតតូច ៦វគ្គ (៦). បច្ចេកទេសធ្វើសួនបន្លែគ្រួសារ ១វគ្គ

**៥.៤.៧. ខេត្តពោធិ៍សាត់** មានចំនួន **១២ វគ្គ៖** (១).កុំព្យូទ័ររដ្ឋបាល ២ វគ្គ (២).ចិញ្ចឹមនិងព្យាបាលមាន់៣វគ្គ (៣).សួនដំណាំជាលក្ខណៈគ្រួសារ ៣វគ្គ (៤). បច្ចេកទេសថែទាំគ្រឿងយន្តកសិកម្ម ៤ វគ្គ ។

**៥.៤.៨. ខេត្តកំពត** មានចំនួន **១១ វគ្គ៖** (១).ចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ ៤ វគ្គ (២).បច្ចេកទេសចិញ្ចឹមត្រីអណ្តែង ៣ វគ្គ (៣). បច្ចេកទេសថែទាំគ្រឿងយន្តកសិកម្ម ៤ វគ្គ ។

**៥.៤.៩. ខេត្តកំពង់ធំ** មានចំនួន **៧ វគ្គ៖** (១). ថែទាំគ្រឿងយន្តកសិកម្ម ៤ វគ្គ (២). ការផលិតសាប៊ូលាងចាន ២ វគ្គ (៣).ចិញ្ចឹមមាន់លក្ខណៈគ្រួសារ ១ វគ្គ។

**១០. ខេត្តបន្ទាយមានជ័យ** មានចំនួន **៤** វគ្គ ៖ (១). ការជួសជុល និងថែទាំគ្រឿងយន្តកសិកម្មខ្នាតតូច ៣ វគ្គ (២).ភ្លេងពិនពាទ្យ ១ វគ្គ

**៥.៤.១១. ខេត្តសៀមរាប** មានចំនួន **៨ វគ្គ៖** (១). ធ្វើជីកំប៉ុស្ដិ៍ ២ វគ្គ (២).សាប៊ូលាងចាន ២ វគ្គ (៣)ថែទាំនិងជួសជុលគ្រឿងយន្តកសិកម្ម ៤ វគ្គ

**៥.៤.១២. ខេត្តកំពង់ឆ្នាំង** មានចំនួន **៨ វគ្គ៖** (១). ថែទាំគ្រឿងយន្តកសិកម្មខ្នាតតូច ៦ វគ្គ (២). សាប៊ូលាងចាន ២ វគ្គ។

**៥.៤.១៣. ខេត្តកណ្តាល** មានចំនួន **២ វគ្គ៖** (១). សួនដំណាំបន្លែគ្រួសារ ២ វគ្គ (២). បច្ចេកទេសចិញ្ចឹមមាន់ ២ វគ្គ។

## ៦. ការសន្និដ្ឋាន

ការអភិវឌ្ឍធនធានមនុស្ស និងពង្រឹងសមត្ថភាពរបស់មន្ត្រីរាជការឱ្យឆ្លើយតបនឹងតម្រូវការជំនាញ និងនិន្នាការរីកចម្រើនសេដ្ឋកិច្ច សង្គមនិងបច្ចេកវិទ្យាគឺជា ការចាំបាច់ក្នុងការអនុវត្តការងារឱ្យទទួលបានជោគជ័យតាមគោលដៅ និងធានាឱ្យមាននិរន្តរភាពការងារអង្គភាពនានានៃក្រសួងអភិវឌ្ឍន៍។ ដោយឡែកការ បបបណ្តុះបណ្តាលជំនាញមូលដ្ឋានជូនប្រជាពលរដ្ឋជនបទ គឺការរួមចំណែកយ៉ាងសំខាន់បំផុតក្នុងការលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ ដែលជាមូលដ្ឋានកាត់បន្ថយភាពក្រីក្រនៅតាមជនបទ។ យោងតាមការខិតខំប្រឹងប្រែងតាមតួនាទី និងភារកិច្ចនៅក្នុងឆ្នាំ ២០២២ នាយកដ្ឋានបណ្តុះបណ្តាល និងស្រាវជ្រាវ បានសម្រេចលទ្ធផលសំខាន់ៗដូចមាននៅក្នុង ចំណុច **៣** ក្នុងរបាយការណ៍នេះ។ លទ្ធផលដែលសម្រេចបានខាងលើនេះ ជាការចូលរួមចំណែកក្នុងការលើកកម្ពស់សមត្ថភាពមន្ត្រីរាជការ និង

ប្រជាជន ដើម្បីបុព្វហេតុ កាត់បន្ថយភាពក្រីក្រ ស្របតាមយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល តាមរយៈការផ្តល់ជូនសេវាបណ្តុះបណ្តាល និងការបង្កើតមុខរបរ ឬការបង្កើនបំណិនជីវិតដែលជួយកាត់បន្ថយការចំណាយក្នុងជីវភាពប្រចាំថ្ងៃចំពោះប្រជាពលរដ្ឋ ដែលបានទទួលវគ្គបណ្តុះបណ្តាលជំនាញមូលដ្ឋាន៕